# មេរៀនទី ១៥៣: នេហេមាទូលអង្វរព្រះឲ្យអត់ទោសដល់សាសន៍អ៊ីស្រាអែល

## នេហេមា ១:១-២:៩

**គោលបំណង៖** ព្រះស្តារយើងឡើងវិញ។

**ខគម្ពីរចងចាំ៖ អេសាយ ៤០:៣១** *"តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច គេនឹងហើរឡើងទៅលើដោយស្លាបដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

អំពើបាបបំផ្លាញជីវិតរស់នៅរបស់យើង និងរុញយើងឲ្យចេញឆ្ងាយពីព្រះ។ តើអ្នកត្រូវការឲ្យព្រះស្តារឡើងវិញនូវផ្នែកណាមួយនៅក្នុងជីវិតរបស់យើងដែរឬទេ? នេហេមាបានស្រមៃក្នុងការស្តារកំផែងទីក្រុងឡើងវិញ ហើយគាត់ក៏បានសុំឲ្យស្តេចអនុញ្ញាតឲ្យគាត់ធ្វើការនោះ។ សូមស្វែងរកកន្លែងស្ងាត់ណាមួយ ហើយអធិស្ឋានពីការនេះ។ ឱព្រះវរបិតា ខ្ញុំចង់ចាប់ផ្តើមស្តារការងារឡើងវិញ (សូមរៀបរាប់ពីអ្វីដែលអ្នកចង់ស្តារឡើងវិញ)។សូមអរគុណដល់ព្រះជាម្ចាស់ដែលទ្រង់បានឮពីការអធិស្ឋានរបស់ពួកយើង ហើយសូមជួយកូនឲ្យស្តារនូវការបែកបាក់រវាងពួកយើងផងដែរ។

**ចំរៀង៖** ១. ព្រះនឹងរៀបចំផ្លូវ ២. ខ្ញុំអាចធ្វើគ្រប់ការ ៣. ចូរមានកម្លាំងនិងមានចិត្តក្លាហានចុះ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «ដើរជើង៤»



១. ចែកកុមារជា ៣ក្រុមស្មើគ្នា។
២. គ្រូត្រូវដាក់ទីចម្ងាយ ៤ម៉ែត្រពីចំនុចចាប់ផ្តើម។
៣. នៅពេលដែលគ្រូស្រែក ១ ២ ៣ កុមារ ៣នាក់មកពីក្រុមនីមួយៗ ត្រូវដើរជើង ៤ ដោយផ្ងាររហូតទៅដល់ទី។ ពេលទៅដល់ទីរួចគេត្រូវរត់ត្រឡប់មកទីចាប់ផ្តើមវិញ ហើយប៉ះកុមារបន្ទាប់ឲ្យលេងបន្ត។



៤. ក្រុមណាដែលអាចលេងបានគ្រប់គ្នាមុន ក្រុមនោះជាអ្នកឈ្នះ។
៥. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងដឹងថាល្បែងនេះគឺពិបាកលេង ប៉ុន្តែពួកគេនៅតែអាចលេងល្បែងនេះចប់។ ក៏ដូចគ្នានេះដែរ យើងគិតថាវាពិបាកនៅក្នុងជីវិតរស់នៅរបស់យើង ប្រសិនបើយើងទុកចិត្តព្រះហើយបន្តធ្វើវា នោះព្រះនឹងស្តារយើងឡើងវិញ។

### ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់ធ្វើឲ្យបែករបស់អ្វីមួយដែរឬទេ? តើអ្នកអាចជួសជុលវា ហើយធ្វើឲ្យវាថ្មីឡើងម្តងទៀតដែរឬទេ? ព្រះមិនចង់ឃើញយើងមានការបែកបាក់នោះទេ។ ព្រះតែងតែចង់ស្តារយើងឡើងវិញ និងធ្វើឲ្យយើងល្អប្រសើរ។ ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ ដែលបានអធិស្ឋានទៅព្រះឲ្យជួយស្តារជនជាតិអ៊ីស្រាអែលឡើងវិញពីការបាក់បែក។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីរបានប្រាប់យើងពីទីក្រុងដ៏ស្រស់ស្អាត ដែលបង្កើតឡើងដោយមនុស្សរបស់ព្រះនៅឯយេរូសាឡិម។ ពួកមនុស្សទាំងនោះបានការពារទីក្រុងរបស់ពួកគេដោយប្រើកំផែង។ មួយរយៈនោះមនុស្សគឺមិនបានស្រលាញ់អ្វីជាជាងការដែលបម្រើ និងថ្វាយបង្គំព្រះនោះទេ។ ពួកគេត្រូវបានគេស្គាល់ថាជារាស្ត្ររបស់ព្រះ។ ប៉ុន្តែបន្ទាប់មកពួកគេចាប់ផ្តើមភ្លេចបម្រើព្រះ។ ពួកគេសម្រេចចិត្តធ្វើតាមចិត្តខ្លួនឯងជំនួសវិញ។ ព្រះក៏បានដាក់ទោសពួកគេ ដើម្បីជួយឲ្យពួកគេរៀនពីសារៈសំខាន់នៃការបម្រើ និងថ្វាយបង្គំព្រះអង្គ។ ដូច្នេះព្រះបានអនុញ្ញាតឲ្យប្រទេសមួយដែលមានឈ្មោះថា បាប៊ីឡូនឲ្យចូលមកយកទឹកដីរបស់ពួកគេ។ ហើយសត្រូវក៏បានវាយបំបែកកំផែងជុំវិញទីក្រុងទាំងមូល។

ឥឡូវនេះបាប៊ីឡូនត្រូវបានគ្រប់គ្រងដោយប្រទេសដែលមានឈ្មោះថា ពើស៊ី។ នេហេមាគឺជាម្នាក់ដែលបានរស់នៅក្នុងស្រុកពើស៊ី។ នេហេមាគឺជាអ្នកថ្វាយពែង។ ក្នុងនាមជាអ្នកថ្វាយពែងគឺមិនមែនមានន័យថា គាត់កាន់តែពែងរបស់ស្តេចនោះទេ ប៉ុន្តែគាត់ក៏ត្រូវតែភ្លក្សគ្រប់របស់ទាំងអស់មុននឹងយកឲ្យស្តេចសោយដែរ។ ដូច្នេះ បើសិននៅក្នុងទឹកទាំងអស់នោះមានជាតិពុលនេហេមាគឺអាចឈឺ និងស្លាប់បាន ប៉ុន្តែស្តេចនឹងត្រូវបានសង្គ្រោះ។

នៅពេលដែលនេហេមាបានលឺពីអ្វីដែលបានកើតឡើងចំពោះកំផែងទីក្រុងយេរូសាឡិម គាត់គឺពិបាកចិត្តជាខ្លាំង។ គាត់បានអធិស្ឋានទៅព្រះសុំឲ្យព្រះអត់ទោសដល់ជនជាតិអ៊ីស្រាអែលដែលពួកគេបានភ្លេចបម្រើព្រះ។ នេហេមាបានមានផែនការមួយក្នុងការស្តារកំផែងជុំវិញក្រុងយេរូសាឡិមឡើងវិញ។ ប៉ុន្តែគាត់ដឹងថា គាត់ត្រូវការជំនួយរបស់ស្តេចរបស់ស្រុកពើស៊ី។

ជាធម្មតានេហេមាជាអ្នកថ្វាយពែងដ៏សប្បាយរីករាយម្នាក់។ ប៉ុន្តែថ្ងៃមួយនេហេមាមកធ្វើការទាំងទឹកមុខក្រៀមក្រំ។ ការដែលបង្ហាញទឹកមុខក្រៀមក្រំនៅចំពោះមុខស្តេចប៉ុន្មានថ្ងៃអាចធ្វើឲ្យអ្នកអស់ជីវិតបាន។ ប៉ុន្តែ ស្តេចគឺពិតជាស្រលាញ់និងទុកចិត្តនេហេមាជាខ្លាំង ហើយទ្រង់បានសួរគាត់ថា ហេតុអ្វីបានជាអ្នកក្រៀមក្រំម្លេះ។ នេហេមាក៏ប្រញាប់អធិស្ឋានទៅកាន់ព្រះនិងពន្យល់ទៅកាន់ស្តេចថា គាត់មានការពិបាកចិត្តដោយព្រោះតែកំផែង និងទ្វាររបស់ទីក្រុងយេរូសាឡិម ជាទីក្រុងនៃជាតិសាសន៍របស់ខ្លួនត្រូវបានកម្ទេច។ នេហេមាក៏ចាប់ប្រាប់ទៅស្តេចពីផែនការរបស់គាត់ថា ខ្លួនចង់ទៅទីក្រុងយេរូសាឡិមដើម្បីស្តារទីក្រុងឡើងវិញ ហើយស្តេចក៏បានយល់ព្រមជាមួយសំណើររបស់គាត់ និងបានសន្យាថានឹងជួយដល់គាត់ថែមទៀតផង!

នេហេមាបានផ្លាស់ប្តូរពីការដែលក្រៀមក្រំមកជាសប្បាយរីករាយ ដោយព្រោះព្រះបានឆ្លើយតបនឹងការអធិស្ឋានរបស់គាត់។ ហើយនៅក្នុងភាពសប្បាយរីករាយរបស់គាត់ នេហាមាក៏មានការរវល់ក្នុងការរៀបចំផែនការស្តារកំផែងទីក្រុង ដើម្បីបង្កើតកំផែងទីក្រុងថ្មីឲ្យដូចកំផែងចាស់ពីមុន។ នេហេមាបានដឹងថា គាត់គួរតែទុកចិត្តលើព្រះ ព្រោះទ្រង់ជាអ្នកដែលស្តារយើងទាំងអស់គ្នាឡើងវិញ។

ព្រះគឺជាម្នាក់ដែលបានជួយពួកយើង នៅពេលដែលយើងមានការបាក់បែក និងមានបញ្ហាផងដែរ។ ព្រះគឺជាម្នាក់ដែលបានស្តារពួកយើងទាំងអស់គ្នា ប៉ុន្តែពេលខ្លះព្រះបានប្រើមនុស្សដែលមានចិត្តល្អ ដែលជាអ្នកជួយដូចជាស្តេចនៅក្នុងរឿងនៅក្នុងព្រះគម្ពីររបស់យើង គឺជាអ្នកដែលបានជួយដល់នេហេមា និងមនុស្សរបស់គាត់។ យើងសរសើរតម្កើងព្រះដែលទ្រង់តែងតែជួយយើងឲ្យស្តារនូវអ្វីដែលបានខូចពីមុន!

## ៦. សំនួរពិភាក្សា

១. ហេតុអ្វីបានជាទីក្រុងយេរូសាឡិមត្រូវបានកម្ទេច?
*ព្រោះពួកគេមិនបានស្តាប់បង្គាប់ព្រះ ព្រះបានឲ្យប្រទេសដទៃគ្រប់គ្រង និងកម្ទេចទីក្រុងនោះ*
២. តើនេហេមាគឺជានរណា? *គាត់គឺជាជនជាតិយូដាដែលធ្វើជាអ្នកថ្វាយពែងឲ្យស្តេច ពើស៊ី*
៣. តើនេហេមាចង់ធ្វើអ្វី?
*គាត់ចង់ត្រឡប់ទៅយេរូសាឡិមនិងស្តារទីក្រុងឡើងវិញ ដោយការកសាងឡើងវិញនូវកំផែងជុំវិញទីក្រុង*
៤. តើផ្នែកណាមួយនៅក្នុងជីវិតរបស់អ្នកដែលត្រូវការ ជុសជុល និងការស្តារឡើងវិញពីព្រះឥឡូវនេះ?
*ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ច្រាំង និងទន្លេ»




១. គ្រូត្រូវគូរបន្ទាត់ពីរ មួយដែលនៅខាងក្រៅបន្ទាត់ ហៅថា "ច្រាំង" និងនៅក្នុងបន្ទាត់ហៅថា "ទន្លេ"
២. ចែកកុមារជាពីរក្រុមហើយឲ្យពួកគេឈរពីលើច្រាំង
៣. នៅពេលដែលគ្រូស្រែកថា "ទន្លេ" កុមារត្រូវតែលោតចូលទៅក្នុងទន្លេ។ នៅពេលដែលគ្រូនិយាយថា "ច្រាំង" ត្រូវតែលោតចេញពីទន្លេ។ គ្រូត្រូវស្រែកដដែលៗ ដើម្បីឲ្យកុមារមានការភ័ន្តច្រឡំ។




៤. ប្រសិនបើកុមារណាធ្វើខុសពីការណែនាំនោះគេនឹងចាញ់ល្បែងនេះ។
៥. បន្តលេងល្បែងនេះ រហូតនៅសល់កុមារតែម្នាក់ជាអ្នកឈ្នះ។
៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពួកគេត្រូវតែស្តាប់គ្រូដោយយកចិត្តទុកដាក់ តាមលំដាប់លំដោយ ដើម្បីកុំឲ្យអ្នកបង្កើតកំហុស។ ក៏ដូចគ្នានេះដែរ យើងត្រូវតែស្តាប់តាមព្រះដោយយកចិត្តទុកដាក់ពីព្រោះព្រះតែងតែចង់ស្តារយើងឡើងវិញ។

## ៨. ខគម្ពីរចងចាំ អេសាយ ៤០:៣១

## ៩. ហត្ថកម្ម ផាត់ពណ៌រូបភាព "នេហេមាអធិស្ឋានសម្រាប់ទីក្រុងយេរូសាឡិម"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# នេហេមាអធិស្ឋានសម្រាប់ទីក្រុងយេរូសាឡិម

